ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ០០៣ សជណ.សហវ.ពដ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ១៩៩៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសសូមប្រកាសដំណឹងជំរាបជូនឯកឧត្តម លោក លោកស្រី និង ប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិលើដីធ្លីមិនបានប្រើប្រាស់ឱ្យបានជ្រាបថា :

- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវអនុវត្តបើកទូលាយក្នុងក្របខ័ណ្ឌខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជាតាមសេចក្តីសំរេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ គឺជាថ្ងៃចាប់ផ្តើមប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់សំរាប់ឆ្នាំ១៩៩៩ ) ។

- ពន្ធនេះត្រូវបង់តាមអត្រា ២% លើថ្លៃដីគិតតាមទីផ្សារវាយតម្លៃទៅតាមថ្លៃគិតក្នុងមួយម៉ែត្រក្រឡាកំណត់សំរាប់ឆ្នាំនិមួយៗ ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

- ម្ចាស់កម្មសិទ្ធិលើដីធ្លីមិនបានប្រើប្រាស់និមួយៗ មានភារកិច្ចធ្វើលិខិតប្រកាសបង់ពន្ធចំនួន២ច្បាប់ ជូនដល់ស្នាក់ការពន្ធដារនៅក្នុងតំបន់ដែលមានដីត្រូវជាប់ពន្ធ ។ ក្នុងការគិតពន្ធត្រូវបានអនុញ្ញាតិឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន ១.២០០ម៉ែត្រក្រឡា ក្នុងដីមួយកន្លែង ។

- ការមិនបានធ្វើប្រកាសសារពើពន្ធ ការបង់ពន្ធមិនគ្រប់ ឬ ការមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវទទួលរងទោសទ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធជាធរមាន ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គណៈកម្មការ,អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់គ្រប់ខេត្ត-ក្រុងរង់ចាំទទួលដោះស្រាយនូវរាល់ចម្ងល់ទាំងឡាយ ទាក់ទិននឹងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និង មានក្តីសង្ឃឹមជឿជាក់ថា ឯកឧត្តម អស់លោក លោកស្រី និង ប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិលើដីធ្លីមិនបានប្រើប្រាស់ទាំងអស់ប្រាកដជាបានយល់និងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អប្រសើរជាពុំខានឡើយ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់